**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ៧១៧ ព.ណ.ឯ.ស.ស

ថ្ងៃ ចន្ទ ៨ កើត ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០

# សេចក្តីជូនដំណឹង

## ស្តីពី

## ថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយ

- យោងប្រកាសអន្តរក្រសួងលេខ១៧២ពណ.អវប.ប្រក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និងថាមពល ស្តីពីការកំណត់រូបមន្តសម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា
- យោងលើការព្រមព្រៀង លើរូបមន្តកំណត់តម្លៃជាមួយក្រុមហ៊ុនប្រេងឥន្ធនៈដែលប្រកបអាជីវកម្មនៅកម្ពុជា
- យោងការប្រែប្រួលនៃតម្លៃប្រេងឥន្ធនៈលើទីផ្សារក្នុងតំបន់ និងអន្តរជាតិ

ផ្អែកតាមតម្លៃមធ្យមប្រេងឥន្ធនៈលើទីផ្សារអន្តរជាតិ ថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី១៦ ដល់៣១ ខែមីនា ឆ្នាំ២០២០ នឹងត្រូវលក់៣.២១០រៀល/១លីត្រ សម្រាប់សាំងធម្មតា EA92 និង ២.៩៥៩រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត។

ដើម្បីជួយសម្រួលដល់ជីវភាពរបស់ប្រជាជន និងដោយមានការរួមចំណែកពីក្រុមហ៊ុនចែកចាយប្រេងឥន្ធនៈនៅកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចបញ្ចុះតម្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា ចំនួន៤សេនដុល្លារ/លីត្រ ។

ដូច្នេះថ្លៃលក់រាយប្រេងឥន្ធនៈសម្រាប់អនុវត្ត **ចាប់ពីថ្ងៃទី១៦ ដល់៣១ ខែមីនា ឆ្នាំ២០២០** នឹងចុះមក៣.០៥០ រៀល/លីត្រ សម្រាប់សាំងធម្មតា EA92 និង ២.៨០០រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត ។

ការគណនាថ្លៃលក់រាយប្រេងឥន្ធនៈមានលម្អិតដូចតារាងខាងក្រោម៖

**តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារកម្ពុជា**

| ល.រ | អធិប្បាយ | ប្រេងសាំងធម្មតា/លីត្រ (Gasoline 92) | ប្រេងម៉ាស៊ូត/លីត្រ (Gasoil) |
|---|---|---|---|
| ១ | Average MOPS | ០,៣០៦២ដុល្លារ | ០,៣៣៥៤ ដុល្លារ |
| ២ | ពន្ធ៖ | ០,១៧៥១ ដុល្លារ | ០,០៦៥៦ ដុល្លារ |
| | ពន្ធគយ | ០,០៧២៦ ដុល្លារ | ០,០០០០ ដុល្លារ |
| | អាករបន្ថែម | ០,០២០០ ដុល្លារ | ០,០៤០០ ដុល្លារ |
| | អាករពិសេស | ០,០៨២៥ ដុល្លារ | ០,០២៥៦ ដុល្លារ |
| ៣ | PREMIUM | ០,២០ ដុល្លារ | ០,២៣ ដុល្លារ |
| ៤ | អាករលើតម្លៃបន្ថែម (១០% នៃ ១+២+៣) | ០,០៦៨៥ ដុល្លារ | ០,០៦៣៥ ដុល្លារ |
| ៥ | ថ្លៃលក់រាយ/លីត្រ (គិតជាដុល្លារ) | ០,៧៥៣៩ ដុល្លារ | ០,៦៩៨៦ ដុល្លារ |
| ៦ | ថ្លៃលក់រាយ/លីត្រ (គិតជារៀល) | ៣.០៤៨ រៀល | ២.៨២៤ រៀល |
| ៧ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជាដុល្លារ) | ០,៧៥ ដុល្លារ | ០,៧០ ដុល្លារ |
| ៨ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជារៀល) | ៣.០៥០ រៀល | ២.៨០០ រៀល |

សម្គាល់៖ អត្រាប្តូរប្រាក់ផ្លូវការ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០ ដែលស្មើនឹង ៤០៤៣រៀល/ដុល្លារអាមេរិក


ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩

Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

## តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ

| ថ្ងៃខែឆ្នាំ | ប្រេងសាំងធម្មតា/ធុង EA 92 (USD/Barrel) | ប្រេងម៉ាស៊ូត/ធុង DO 0.05% (USD/Barrel) |
|---|---|---|
| ២ មីនា ២០២០ | ៥៥,៧៩ | ៦០,៦៤ |
| ៣ មីនា ២០២០ | ៥៧,៣៦ | ៦១,១៨ |
| ៤ មីនា ២០២០ | ៥៦,៤០ | ៥៩,៩២ |
| ៥ មីនា ២០២០ | ៥៦,៨៧ | ៥៩,៩៦ |
| ៦ មីនា ២០២០ | ៥៤,៨៤ | ៥៧,៧២ |
| ៩ មីនា ២០២០ | ៤២,៦៥ | ៤៦,១២ |
| ១០ មីនា ២០២០ | ៤៣,៧៣ | ៤៨,០៦ |
| ១១ មីនា ២០២០ | ៤២,៥៣ | ៤៩,០៦ |
| ១២ មីនា ២០២០ | ៣៩,៤០ | ៤៤,៨៥ |
| ១៣ មីនា ២០២០ | ៣៧,៣៥ | ៤៥,៨៥ |
| មធ្យមភាគ ១០ថ្ងៃ | ៤៨,៦៩២០ | ៥៣,៣៣៦០ |
| មធ្យមភាគ (ដុល្លារ/លីត្រ) | ០,៣០៦២ | ០,៣៣៥៤ |

### ក្រាហ្វិកបម្រែបម្រួលថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី០១ ខែមករា ដល់ ១៦ ខែមីនា ឆ្នាំ២០២០



សូមបញ្ជាក់ថា ក្រសួងពាណិជ្ជកម្មមិនមែនជាអ្នកកំណត់ថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជាទេ គឺក្រសួងគ្រាន់តែស្រង់តម្លៃឡើង-ចុះ នៃប្រេងតាមទីផ្សារអន្តរជាតិ មកគណនាតាមប្រកាសដូចមានក្នុងឯកសារយោងខាងលើតែប៉ុណ្ណោះ ។

អាស្រ័យហេតុនេះ សូមសាធារណៈជនមេត្តាជ្រាបជាព័ត៌មាន និងសូមគ្រប់ស្ថានីយលក់រាយប្រេងឥន្ធនៈទាំងអស់ប្រតិបត្តិតាមការចាំបាច់ ។